រាជបណ្ឌិត្យសភាកម្ពុជា

# តួនាទីតុលាការរដ្ឋបាលប្រទេសកម្ពុជា
# ឆ្នាំ២០១៤-២០១៦

## THE ROLE OF THE ADMINISTRATIVE COURT OF CAMBODIA 2014-2016

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ 0003384
រាជបណ្ឌិត្យសភាកម្ពុជា

ឥន យឿន

និក្ខេបបទបណ្ឌិត
ជំនាញ នីតិសាស្ត្រ

សាស្ត្រាចារ្យណែនាំ បណ្ឌិតសភាចារ្យ ខ្លួត ធីតា

ភ្នំពេញ ២០១៨

# មាតិកា

ទំព័រ


-ឧទ្ទិសស្នាដៃ ..... i
-សេចក្ដីថ្លែងអំណរគុណ ..... ii
-អំណះអំណាង ..... iv
-មូលន័យសង្ខេប ..... v
-Abstract ..... vi
-និក្ខេបបទសង្ខេប ..... vii
-Thesis Summary ..... xi
-អារម្ភកថា ..... xv
-សេចក្ដីផ្ដើម ..... ១


## ជំពូកទី១

## ទិដ្ឋភាពទូទៅនៃតួនាទីតុលាការរដ្ឋបាលប្រទេសកម្ពុជា


១.១-តួនាទីតុលាការរដ្ឋបាល និងតុលាការស៊ីវិល ..... ១០
១.១.១-តួនាទីតុលាការរដ្ឋបាល ..... ១០
១.១.២-តួនាទីតុលាការស៊ីវិល ..... ១២
១.២-អ្វីទៅជាវិវាទរដ្ឋបាល? ..... ១៣
១.២.១-អត្ថន័យវិវាទរដ្ឋបាល ..... ១៤
១.២.២-ឧបាស្រ័យក្នុងវិវាទរដ្ឋបាល ..... ១៧
១.២.៣-និយមន័យពាក្យ«ឧបាស្រ័យ» ..... ១៧
១.២.៤-ប្រភេទឧបាស្រ័យ ..... ១៨
១.២.៥-ការជ្រើសរើសមធ្យោបាយធ្វើការតវ៉ា ..... ២០
១.៣-សញ្ញាណទូទៅនៃតួនាទីតុលាការរដ្ឋបាល ..... ២១
១.៣.១-មូលដ្ឋានគតិយុត្តនៃវិវាទរដ្ឋបាល ..... ២១
១.៣.២-គោលការណ៍នៃសេរីភាពប្រើប្រាស់ឧបាស្រ័យ ..... ២៥
១.៣.៣-យុត្តាធិការរដ្ឋបាល ..... ២៦
១.៣.៤-ភាពខុសគ្នារវាងយុត្តាធិការរដ្ឋបាល និងយុត្តាធិការធម្មតា ..... ២៨
១.៣.៥-ភាគីជម្លោះរឿងក្ដីរដ្ឋបាល ..... ២៩
១.៤-រឿងក្ដីរដ្ឋបាលដែលមិនស្ថិតនៅក្នុងយុត្តាធិការរដ្ឋបាល ..... ៣០
១.៤.១-រឿងក្ដីរដ្ឋបាលទាក់ទងវិន័យរបស់ចៅក្រម និងព្រះរាជអាជ្ញា ..... ៣០
១.៤.២-ករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត ..... ៣៣
១.៤.៣-រឿងក្ដីរដ្ឋបាលទាក់ទងវិន័យរបស់យោធិន ..... ៣៤
១.៥-ប្រវត្តិនៃតុលាការប្រទេសកម្ពុជា ..... ៣៤
១.៥.១-តុលាការសម័យហ្វូណន ..... ៣៦
១.៥.២-តុលាការសម័យចេនឡា ..... ៣៨

១.៥.៣-តុលាការសម័យអង្គរ ........ ៣៩
១.៥.៤-ប្រវត្តិធម្មសាស្ត្រក្នុងសម័យអង្គរ ........ ៤២
១.៥.៥-ប្រវត្តិធម្មសាស្ត្រក្នុងសម័យក្រោយអង្គរ ........ ៤៣
១.៥.៦-រចនាសម្ព័ន្ធតុលាការសម័យបុរាណ ........ ៤៣
១.៥.៧-មន្ត្រីទទួលបន្ទុកវិស័យតុលាការ ........ ៤៨
១.៥.៨-ប្រភេទវិវាទនៅសម័យបុរាណ ........ ៥៧
១.៥.៩-នីតិវិធីជំនុំជម្រះក្តីនៅសម័យបុរាណ ........ ៦១
១.៥.១០-ចំណាត់ថ្នាក់នៃទោស ........ ៧០
១.៥.១១-ការផ្តន្ទាទោស ........ ៧២
១.៥.១២-តុលាការសម័យលង្វែក និងអាណានិគមបារាំង ........ ៧៦
១.៥.១៣-នីតិវិធីវិនិច្ឆ័យសេចក្តីរបស់ចៅក្រម ........ ៧៩
១.៥.១៤-ល្បិចនៃចៅក្រមជំនុំជម្រះក្តី ........ ៨០
១.៥.១៥-នីតិវិធីការធ្វើពិសោធដើមចោទ និង ចុងចម្លើយ ........ ៨១
១.៦-រចនាសម្ព័ន្ធតុលាការកម្ពុជាបច្ចុប្បន្ន ........ ៨២
១.៧-រចនាសម្ព័ន្ធអង្គការតុលាការរដ្ឋបាលប្រទេសប្រើច្បាប់ Common Law ........ ៨៥
១.៧.១-ប្រវត្តិសង្ខេបនៃប្រព័ន្ធច្បាប់ Common Law ........ ៨៦
១.៧.២-ស្ថាប័នតុលាការនៃប្រព័ន្ធ Common Law បែបទំនើប ........ ៨៨
១.៨-រចនាសម្ព័ន្ធអង្គការតុលាការប្រទេសប្រើច្បាប់ Civil Law ........ ៩១
១.៨.១-ប្រវត្តិសង្ខេបនៃប្រព័ន្ធច្បាប់ Civil Law ........ ៩១
១.៨.២-ស្ថាប័នតុលាការនៃប្រព័ន្ធច្បាប់ Civil Law បែបទំនើប ........ ៩៤
១.៩-ប្រៀបធៀបប្រព័ន្ធច្បាប់ Common Law និង Civil Law ........ ៩៤
១.៩.១-អំណាចធ្វើសេចក្តីសម្រេច និងអំណាចធ្វើច្បាប់ ........ ៩៤
១.៩.២-អំណាចដាក់ឱ្យអនុវត្ត ........ ៩៥
១.៩.៣-ការពិនិត្យឡើងវិញកិច្ចរដ្ឋបាល ........ ៩៦
១.៩.៤-ការសើរើរដ្ឋធម្មនុញ្ញ ........ ៩៦
១.៩.៥-រចនាសម្ព័ន្ធតុលាការប្រទេសបារាំង(ប្រើច្បាប់ Civil Law) ........ ៩៧
១.១០-ប្រព័ន្ធតុលាការរដ្ឋបាលប្រទេសចិន ........ ៩៨
១.១០.១-វិសាលភាពនៃការទទួលយកសំណុំរឿងក្តី ........ ៩៩
១.១០.២-វិវាទដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចតុលាការរដ្ឋបាល ........ ១០០

## ជំពូកទី២

## ការវិវត្តន៍នៃតួនាទីតុលាការរដ្ឋបាលប្រទេសកម្ពុជា

២.១-ឧបាស្រ័យវិវាទតាមផ្លូវរដ្ឋបាល ........ ១០១
២.១.១-ឧបាស្រ័យតាមផ្លូវរដ្ឋបាល ឬឧបាស្រ័យគ្មានវិវាទ ........ ១០១
២.១.២-របបគតិយុត្តនៃការធ្វើបណ្តឹងរដ្ឋបាល ........ ១០១
២.១.៣-ច្បាប់ផ្តល់អំណាចអាជ្ញាធររដ្ឋបាលដោះស្រាយវិវាទរដ្ឋបាល ........ ១០២

២.១.៤-អត្ថិភាពនៃសេចក្តីសម្រេចរដ្ឋបាល ............ ១០៦
២.១.៥-មិនមែនសេចក្តីសម្រេចរដ្ឋបាល ............ ១០៧
២.២-សេចក្តីសម្រេចតុល្យការភាពរបស់រដ្ឋបាល ............ ១០៨
២.២.១-ភាពស្ងៀមស្ងាត់របស់រដ្ឋបាលសន្មតថាយល់ព្រម ............ ១១០
២.២.២-ភាពស្ងៀមស្ងាត់របស់រដ្ឋបាលសន្មតថាបដិសេធ ............ ១១៣
២.២.៣-ច្បាប់ផ្តល់អំណាចគ្មានដែនកំណត់ដល់រដ្ឋបាល ............ ១១០
២.៣-ការដោះស្រាយវិវាទមន្ត្រីរាជការ ............ ១១១
២.៣-១-កំហុសខាងវិន័យរបស់មន្ត្រីរាជការ ............ ១១១
២.៣-២-នីតិវិធីអនុវត្តទណ្ឌកម្មវិន័យថ្នាក់ទី១ ............ ១១៣
២.៣-៣-នីតិវិធីអនុវត្តទណ្ឌកម្មវិន័យថ្នាក់ទី២ ............ ១១៤
២.៣.៤-នីតិវិធីអនុវត្តវិន័យចំពោះអ្នករាជការជាប់ចោទប្រកាន់ពីបទវិន័យហើយបាត់ខ្លួនរកពុំឃើញ ............ ១១៥
២.៣-៥-យន្តការដោះស្រាយទំនាស់ពាក់ព័ន្ធមុខងារសាធារណៈ ............ ១១៥
២.៣-៦-នីតិវិធីចោទប្រកាន់ក្នុងបណ្តឹងអាជ្ញា ............ ១១៧
២.៤-កំហុស និង ការទទួលខុសត្រូវរបស់រដ្ឋបាល ............ ១១៧
២.៤.១-ការទទួលខុសត្រូវរបស់រដ្ឋបាល ............ ១១៧
២.៤.២-ការទទួលខុសត្រូវដោយមានកំហុស ............ ១២២
២.៤.៣-ការទទួលខុសត្រូវឥតមានកំហុសរបស់ស្ថាប័នរដ្ឋ ............ ១៣៤
២.៥-ការដោះស្រាយវិវាទនៅមូលដ្ឋាន ............ ១៤៦
២.៥.១-យន្តការដោះស្រាយវិវាទនៅមូលដ្ឋាន ............ ១៤៦
២.៥.២-ការដោះស្រាយវិវាទមូលដ្ឋានដោយក្រុមប្រឹក្សា ............ ១៤៧
២.៥.៣-ការបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ក្រុង ស្រុក ខណ្ឌ ............ ១៤៩
២.៥.៤-ការដោះស្រាយវិវាទនៅមូលដ្ឋានដោយរដ្ឋបាលឃុំ សង្កាត់ ............ ១៥០
២.៥.៥-ការដោះស្រាយវិវាទមូលដ្ឋានដោយគណៈកម្មាធិការផ្សេងទៀត ............ ១៥២
២.៦-នីតិវិធីរដ្ឋបាលមិនមែនវិវាទ និងការត្រួតពិនិត្យនីត្យានុកូលភាព ............ ១៥៣
២.៦.១-នីតិវិធីរដ្ឋបាលមិនមែនវិវាទ ............ ១៥៣
២.៦.២-គោលការណ៍នៃនីត្យានុកូលភាព ............ ១៥២
២.៦.៣-កិច្ចរដ្ឋបាល ............ ១៦៦
២.៦.៤-ការកម្រិតព្រំដែនអំណាចរដ្ឋបាល និងយុត្តាធិការ ............ ១៦៧
២.៦.៥-ការរំលោភអំណាច និងទង្វើមិនស្របច្បាប់ ............ ១៧២
២.៦.៦-កិច្ចសន្យាស៊ីវិល និង កិច្ចសន្យារដ្ឋបាលរបស់រាជការ ............ ១៨១
២.៦.៧-លទ្ធកម្មសាធារណៈ ............ ១៨៥
២.៦.៨-កិច្ចព្រមព្រៀងសម្បទាន(contratde concession) ............ ១៩១
២.៧-នីតិវិធីឧបាស្រ័យតាមផ្លូវយុត្តាធិការ ............ ១៩៣
២.៧.១-នីតិវិធីវិវាទរដ្ឋបាលតាមផ្លូវតុលាការ ............ ១៩៣
២.៧.២-ការបែងចែកសមត្ថកិច្ចតុលាការ ............ ១៩៣

២.៧.៣-ការពិនិត្យបញ្ហាដែលកើតមានតាមផ្លូវយុត្តាធិការ ........ ២០០
២.៧.៤-សាលក្រម ឬសាលដីកាសម្រេចសេចក្តី........ ២១៩

# ជំពូកទី៣

# សារសំខាន់នៃតួនាទីតុលាការរដ្ឋបាលប្រទេសកម្ពុជា

៣.១-កំណែទម្រង់ច្បាប់ និង ប្រព័ន្ធតុលាការទាក់ទងតុលាការរដ្ឋបាល........ ២២២
៣.១.១-សារសំខាន់នៃតួនាទីតុលាការរដ្ឋបាល ........ ២២៦
៣.១.២-តុលាការមានអំណាចផ្តន្ទាទោសឱ្យរដ្ឋសងសំណង ........ ២២៧
៣.១.៣-តុលាការមានអំណាចលុបសេចក្តីសម្រេចរដ្ឋបាលតាំងពីតុលាការជាន់ទាប ...... ២២៨
៣.១.៤- ផ្តល់ទំនុកចិត្តចំពោះសាធារណជនចំពោះតួនាទីតុលាការ........ ២២៩
៣.១.៥-ច្បាប់ផ្តល់តួនាទីទៅតុលាការដោះស្រាយរឿងក្តីរដ្ឋបាល ........ ២២៩
៣.១.៦-កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ........ ២៣០
៣.១.៧-ការរៀបចំឱ្យមានតុលាការរដ្ឋបាលលើកដំបូង........ ២៣១
៣.១.៨-បង្កើនសមត្ថភាពចៅក្រម........ ២៣២
៣.១.៩-ចងក្រងយុត្តិសាស្ត្រសម្រាប់តុលាការរដ្ឋបាលនៅពេលខាងមុខ........ ២៣៣
៣.២-បញ្ហាប្រឈម ........ ២៣៤
៣.២.១-តុលាការរដ្ឋបាលមិនទាន់ផ្តាច់ចេញពីតុលាការធម្មតា........ ២៣៤
៣.២.២-តុលាការមិនទាន់ហ៊ានលុបសេចក្តីសម្រេចរដ្ឋបាលដែលមានឋានានុក្រមខ្ពស់... ២៣៥
៣.២.៣-ការអូសបន្លាយពេលវេលានៃការបើកសវនាការ ........ ២៣៥
៣.២.៤-ការខ្វះខាតក្រមនីតិវិធីរដ្ឋបាល និងនីតិវិធីវិវាទរដ្ឋបាល........ ២៣៥
៣.២.៥-ការខ្វះខាតលិខិតបទដ្ឋានគតិយុត្តិ........ ២៣៦
៣.២.៦-ការខ្វះខាតតុលាការជំនាញវិជ្ជាជីវៈ និងបទពិសោធន៍ ........ ២៣៧
៣.២.៧-ការមិនគោរពវិន័យ និង ម៉ោងពេលធ្វើការ........ ២៣៩
៣.២.៨-ភាពមិនឯករាជ្យនៃអំណាចតុលាការ ........ ២៣៩
៣.២.៩-ទម្លាប់បាក់ស្បាតមិនហ៊ានតវ៉ារបស់ប្រជាជន ........ ២៤០
៣.២.១០-កង្វះខាតពត៌មាននិងការស្រាវជ្រាវ........ ២៤០
៣.២.១១-បៀវត្សរបស់មន្ត្រីតុលាការមិនគ្រប់គ្រាន់........ ២៤០
៣.២.១២-ត្រូវការពេលវេលា ........ ២៤១
៣.២.១៣-ជួបបញ្ហាប្រឈមសេដ្ឋកិច្ច........ ២៤១
៣.៣-ដំណោះស្រាយ........ ២៤១
៣.៤-របកគំហើញ........ ២៤៣
៣.៤.១-ការចែងតួនាទីតុលាការឱ្យច្បាស់លាស់ ........ ២៤៣
៣.៤.២-រៀបចំក្រមនីតិវិធីរដ្ឋបាល និងក្រមនីតិវិធីវិវាទរដ្ឋបាល........ ២៤៤
៣.៤.៣-តុលាការដែលមានសមត្ថកិច្ច ........ ២៤៥
៣.៤.៤-ការប្រគល់តួនាទីសាលាជម្រះក្តីជាន់ខ្ពស់លុបសេចក្តីសម្រេចរដ្ឋបាល........ ២៤៥
៣.៤.៥-ចៅក្រមមិនត្រូវមានអំណាចដាក់ទោសលើអាជ្ញធររដ្ឋបាល ........ ២៤៦

៣.៤.៦-អំណាចតុលាការដោះស្រាយវិវាទមុខងារសាធារណៈ.......... ២៤៧
៣.៤.៧-គោលការណ៍អានុភាពឧបាស្រ័យ.......... ២៤៧
៣.៤.៨-អធិបញ្ញារបស់យុត្តាធិការដើម្បីផ្អាកការអនុវត្ត.......... ២៤៨
៣.៤.៩-ករណីអញ្ញត្រកម្មលើអំណាចតុលាការ.......... ២៤៨
៣.៤.១០-បណ្ដឹងទារសំណងខូចខាតនៃការសម្រេចក្ដីខុសរបស់តុលាការ.......... ២៤៨
៣.៤.១១-មិនមែនសេចក្ដីសម្រេចរដ្ឋបាល.......... ២៤៨
៣.៤.១២-សេចក្ដីសម្រេចតុណ្ហីភាពរបស់រដ្ឋបាល.......... ២៤៩
៣.៤.១៣-គោលការណ៍ត្រួតពិនិត្យនីត្យានុកូលភាពនៃកិច្ចរដ្ឋបាលដោយយុត្តាធិការ.......... ២៤៩
៣.៤.១៤-ការសុំផ្អាកការអនុវត្តសេចក្ដីសម្រេចរដ្ឋបាល.......... ២៥០
៣.៤.១៥-សេចក្ដីសម្រេចរបស់តុលារជួយដល់អាជ្ញាធររដ្ឋបាល.......... ២៥០
៣.៤.១៦-អានុភាពនៃសាលក្រម.......... ២៥១
៣.៤.១៧-ការជ្រើសរើសកាលានុវត្តភាពនៃការអនុវត្តសាលក្រម.......... ២៥២
សន្និដ្ឋាន.......... ២៥៣
-គន្ថនិទ្ទេស
-ឧបសម្ព័ន្ធ

# មូលន័យសង្ខេប

ការពង្រឹងការគ្រប់គ្រងរដ្ឋតាមមាគ៌ានីតិរដ្ឋតាមរយៈការបែងចែកអំណាច និងប្រជាធិបតេយ្យដោយតំណាង ត្រូវបានរដ្ឋប្រជាធិបតេយ្យភាគច្រើនទទួលយកជាគោលការណ៍មួយក្នុងការត្រួតត្រាទៅលើការប្រតិបត្តិអំណាចសាធារណៈ។

ប្រទេសដែលប្រកាន់នូវគោលការណ៍នីតិរដ្ឋ ត្រូវឈរលើគោលការបីជាសំខាន់។ ទី១-ប្រទេសត្រូវមានច្បាប់គ្រប់គ្រាន់ដោយមិនខ្វះចន្លោះ ទី២-ត្រូវមានការអនុវត្តច្បាប់ពេញលេញ និងទី៣-ត្រូវមានយន្តការសម្រាប់ការត្រួតពិត្យការអនុវត្តច្បាប់នោះ។ យន្តការសម្រាប់ការត្រួតពិនិត្យការអនុវត្តច្បាប់នេះគឺស្ថាប័នតុលាការរដ្ឋបាលដែលមានតួនាទីនិងអំណាចដើម្បីត្រួតពិនិត្យមើលលើការអនុវត្តច្បាប់ ការលុបសេចក្តីសម្រេចរដ្ឋបាលដែលធ្វើផ្ទុយច្បាប់ និងមានអំណាចធ្វើការផ្តន្ទាទោសទៅលើអ្នករាជការសាធារណៈ ឬអាជ្ញាធររដ្ឋបាលដែលបានធ្វើខុស ឬបានប្រើប្រាស់អំណាចជ្រុល។

ការពិនិត្យឡើងវិញតាមផ្លូវរដ្ឋបាល ជាមូលដ្ឋានគ្រឹះសំខាន់ជាងគេនៅប្រទេសកម្ពុជាបច្ចុប្បន្ន។ ប៉ុន្តែតួនាទីតុលាការរដ្ឋបាលរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ក៏មានសារសំខាន់ខ្លាំងណាស់ដែរដើម្បីជួយត្រួតពិនិត្យនីត្យានុកូលភាពរបស់រដ្ឋបាល និងជួយតម្រង់ទិសដៅរដ្ឋបាល។

តួនាទីតុលាការរដ្ឋបាលក្នុងការពិនិត្យឡើងវិញតាមផ្លូវតុលាការទៅលើការសម្រេចចិត្តរដ្ឋបាលអំពីធម្មនុញ្ញភាព ឬនីត្យានុកូលភាព មានសារសំខាន់ណាស់ចំពោះធម្មានុភាពនៃដំណើរការរដ្ឋបាលក្រោមគោលការណ៍នីតិរដ្ឋ។ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ការត្រួតពិនិត្យសេចក្តីសម្រេចរដ្ឋបាលតាមផ្លូវរដ្ឋបាលដោយខ្លួនឯងដើម្បីលុបចោលសេចក្តីសម្រេចរដ្ឋបាលដែលធ្វើខុសវិញនោះ និងការធ្វើប្តឹងឧបាស្រ័យប្រឆាំងនឹងសេចក្តីសម្រេចរដ្ឋបាលតាមក្រមនីតិវិធីរដ្ឋប្បវេណី និងយុត្តិសាស្ត្រ គឺជានីតិវិធីសំខាន់សម្រាប់ការពិនិត្យឡើងវិញតាមផ្លូវតុលាការ ទោះបីតុលាការរដ្ឋប្បវេណីដើរតួនាទីជាតុលាការរដ្ឋបាលបណ្តោះអាសន្ន និងមិនទាន់បានផ្តាច់តុលាការរដ្ឋបាលចេញពីតុលាការធម្មតាក៏ដោយ។

រហូតមកដល់ពេលនេះវិសាលភាពនៃតួនាទីតុលាការរដ្ឋបាលក្នុងការពិនិត្យឡើងវិញនៅក្រោមបណ្តឹងឧបាស្រ័យនៃវិវាទរដ្ឋបាល ត្រូវបានយកក្រមនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី បទប្បញ្ញត្តិដែលនៅជាធរមានមកប្រើប្រាស់ដើម្បីបំពេញបន្ថែមទៅក្រមនីតិវិធីរដ្ឋបាលដែលមានការខ្វះចន្លោះ។

យុត្តាធិការរបស់តុលាការលើនីតិវិធីបណ្តឹងវិវាទរដ្ឋបាល គឺមានមូលដ្ឋានយ៉ាងច្បាស់ក្រឡែតដែលមានបញ្ញត្តនៅក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែទម្រង់សកម្មភាពជាក់ស្តែងត្រូវស្ថិតក្រោមការសម្រេចចិត្តរបស់ចៅក្រមរដ្ឋបាល។ ទម្រង់ចំបងនៃការពិនិត្យឡើងវិញតាមផ្លូវតុលាការរដ្ឋបាល គឺទម្រង់បណ្តឹងឧបាស្រ័យដែលក្នុងនោះរួមមានទាំងបណ្តឹងវិវាទសុំលុបសេចក្តីសម្រេចរដ្ឋបាល បណ្តឹងសុំផ្អាកឬបញ្ឈប់កិច្ចរបស់អាជ្ញាធររដ្ឋបាល ដែលបណ្តាលមកពីកិច្ចរបស់អ្នករាជការក្នុងការអនុវត្តការងារ ប្រចាំថ្ងៃដែលប៉ះពាល់លើផលប្រយោជន៍ប្រជាជន និងបណ្តឹងដើម្បីសុំទាមទារសំណងនៃអំពើអនីត្យានុកូលភាពនៃអំពើរបស់រាជការឬរដ្ឋបាល ដែលសម្រេចអំពីការផ្តន្ទាទោសលើអាជ្ញាធររដ្ឋបាលនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងនឹងវិវាទរដ្ឋបាល។

គោលបំណងនៃការស្រាវជ្រាវនេះ ដើម្បីកំណត់ច្បាស់លាស់អំពីសារសំខាន់នៃតួនាទីតុលាការរដ្ឋបាលប្រទេសកម្ពុជា និងការបង្កើតឱ្យមានក្រមនីតិរដ្ឋបាល និងក្រមនីតិវិធីនៃដំណើរការដោះស្រាយវិវាទរដ្ឋបាល។ តុលាការដែលធ្លាប់បានធ្វើកន្លងមក រចនាសម្ព័ន្ធមូលដ្ឋាននៃនីតិវិធីវិវាទរដ្ឋបាលរបស់ប្រទេសកម្ពុជា តួនាទី និងនីតិវិធីក្នុងការធ្វើឧបាស្រ័យតាមផ្លូវរដ្ឋបាល និងតាមផ្លូវតុលាការលើការអនុវត្តអំណាចសាធារណៈ។

# Abstract

Strengthening state management by way of the rule of law, through the distribution of power and through democratic representation was adopted by most democratic states as a principle in controlling the exercise of public power.

Countries that adhere to the rule of law shall essentially have three pillars. First, the country must have adequate laws; and (2) there must be full law enforcement; and (3) there must be monitoring mechanisms for the law enforcement. The mechanism for overseeing the implementation of this law is an administrative court with the function and power to oversee the implementation of the law, the power to overturn administrative decisions that are contrary to the law and the power to prosecute public officials or administrative authorities who have done wrong or overreached their power.

Administrative revision is the most fundamental practice of today's Cambodia. But the role of the Cambodian judiciary is still very important to help control administrative legality and help shape the direction of the administration.

The administrative court's role in the judicial review of administrative decisions on constitutionality or legality is crucial to the functioning of the administrative process under the rule of law. In present-day Cambodia, administrative review to revoke incorrect administrative decisions and its appeal procedure under the Code of Civil and Judicial Procedures, as well as strategies, is an essential procedure for judicial review. Although the Civil Court serves as a provisional Administration Court, it has not yet separated the Administrative Court from the ordinary court.

To date, the scope of the administrative courts in reviewing the appeal process of administrative disputes is subject to the applicable civil code procedure, civil codes, and regulations in place to supplement the inadequate administrative procedure.

The court's jurisdiction over administrative proceedings is clearly based on constitutional provisions, but the actual forms of action are subject to a decision of an administrative judge. The main form of judicial review is in the form of grievance, which includes a petition for the revocation of administrative decisions, a petition for a suspension or an end to the administrative authority caused by the civil servants in the performance of the work which is affecting people's interests, and a petition to claim compensation for acts of government or administrative acts which determine the conviction of administrative authorities in the Code of Civil Procedures related to Administrative Disputes.

The purpose of this research is to clarify the importance of the role of the Administrative Court of Cambodia and the establishment of administrative laws and the procedural code for resolving administrative disputes. The Court, which had previously interpreted the basic structure of Cambodia's administrative procedures, has determined the role and procedure for administrative and judicial appeals on the exercise of public power.